# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជានៅសាលាដុនបូស្កូទួលគោក
# ភ្នំពេញថ្មី ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩
## ប្រាជ្ញាញាណជាខ្យល់ដង្ហើមរបស់ព្រះជាម្ចាស់

**អត្ថបទទី១៖ ព្រះប្រាជ្ញាញាណ ៧,២២-៨,១**

ព្រះប្រាជ្ញាញាណ ជាខ្យល់ដង្ហើមរបស់ព្រះជាម្ចាស់ ប្រកបដោយឫទ្ធានុភាព និងជារស្មីដ៏វិសុទ្ធចេញមកពីសិរីរុងរឿង នៃព្រះដ៏ខ្ពង់ខ្ពស់បំផុត។ ប្រាញ ៧,២៥

**ដំណឹងល្អ៖ លូកា ១៧,២០-២៥**

បុត្រមនុស្សនឹងយាងមកប្រៀបបីដូចជាផ្លេកបន្ទោរភ្លឺឆ្វាច ឆ្វូតកាត់ពីជើងមេឃម្ខាងទៅជើងមេឃម្ខាង។ លក ១៧,២៤

បងប្អូនជាទីស្រឡាញ់!

នៅទីនេះ យើងមានសិស្សដែលរៀនលេខាធិការឆ្នាំទីមួយនិងទីពីរ ថ្ងៃនេះខ្ញុំមកសុំព្រះជាម្ចាស់ប្រទានពរសម្រាប់ឆ្នាំសិក្សាថ្មី។ យើងចាប់ផ្តើមដោយថ្វាយអភិបូជា ដែលជាឱកាសមួយដើម្បីទទួលព្រះពរ ដោយសារជីវិតរបស់យើងត្រូវតែមានសេចក្តីសុខ។ សប្តាហ៍មុន ខ្ញុំបានទៅវត្តពុទ្ធសាសនាដើម្បីបង្កើតទំនាក់ទំនងជាមួយលោកយាយលោកតា ជាមួយគណកម្មការវត្តជាមួយព្រះចៅអធិការវត្ត ដោយចែករំលែកគំនិតខ្លះៗនៅក្នុងសាសនា មនុស្សយើងរស់នៅដោយគ្មានសាសនាបន្តិចម្តងៗទៅជាមនុស្សស្ងិត។ យើងមិនមែនជាមនុស្សដែលទទួលចំណេះដឹងដើម្បីចិញ្ចឹមខួរក្បាល យើងមិនមែនជាមនុស្សដែលទទួលជំនាញដើម្បីមានសមត្ថភាពធ្វើការ យើងជាមនុស្សដ៏ពេញលក្ខណៈលុះត្រាតែយើងនឹកឃើញ មនុស្សយើងមានខួរក្បាលផង មានរូបកាយផង និងមានវិញ្ញាណផង។

ដូច្នេះ យើងធ្វើដូចម្តេចដើម្បីចិញ្ចឹមទាំងអស់ នៅក្នុងប្រព័ន្ធអប់រំទាំងមូលរបស់ព្រះសហគមន៍កាតូលិកគឺ មនុស្សយើងត្រូវការមានចំណេះដឹងច្បាស់លាស់ យើងត្រូវការមានជំនាញ។ មនុស្សយើងដើម្បីពេញលក្ខណៈ យើងត្រូវការយកចិត្តទុកដាក់លើរូបកាយ ឲ្យយើងយកចិត្តទុកដាក់លើសុខភាព យើងត្រូវការគិតអំពីទេពកោសល្យរបស់យើង ដើម្បីឲ្យទេពកោសល្យផ្ទាល់ខ្លួនណែនាំឲ្យយើងរីកចម្រើនថែមទៀត។ មួយវិញទៀត យើងត្រូវការបង្កើតទំនាក់ទំនងនៅក្នុងសង្គមយ៉ាងច្បាស់ដែរ មិត្តភាពដែលយើងមានជាមួយបងប្អូនឯទៀតៗនៅក្នុងសង្គម។ ទំនាក់ទំនងជាមួយអ្នកតូចតាច ជាមួយអ្នកក្រីក្រ ជាមួយអ្នកដែលគ្មានសមត្ថភាព យើងត្រូវការបើកភ្នែកថែមទៀត។ ឲ្យយើងចាប់អារម្មណ៍អំពីសង្គមយើង មានអ្វីខ្លះដែលបានកើតឡើងនៅក្នុងសង្គមយើង នៅក្នុងពិភពលោក ចំណេះដឹងរបស់យើងមិនមែនតែមេរៀនដែលយើងទទួល គឺ

មានវប្បធម៌ទូទៅដែលមាននៅក្នុងសង្គមបច្ចុប្បន្ននេះ។ ទាំងសង្គមនៅក្នុងប្រទេសកម្ពុជា ទាំងនៅទ្វីបអាស៊ី ទាំងនៅលើពិភពលោក ដើម្បីឲ្យយើងចាប់អារម្មណ៍ឲ្យយើងមានគំនិតថ្មី ដើម្បីឲ្យយើងទៅជាមនុស្សយ៉ាងពេញលក្ខណៈ។

មនុស្សយើងប្រសិនបើយើងដាច់ដង្ហើមយើងស្លាប់ហើយ ដង្ហើមពិសេសដែលយើងមានគឺផ្លូវវិញ្ញាណ ទោះបីយើងកាន់សាសនាណាក៏ដោយយើងមានផ្លូវវិញ្ញាណ ដែលត្រូវតែយកចិត្តទុកដាក់។ ឲ្យយើងចេះយកពេលវេលាដើម្បីអធិដ្ឋាន ដើម្បីអង្គុយស្ងៀមស្ងាត់ ហើយគិតអំពីអត្ថន័យនៃជីវិតរបស់យើង។ នៅក្នុងអត្ថបទទីមួយ ណែនាំឲ្យយើងមានកម្លាំងសម្រាប់ពេញមួយឆ្នាំ "**ប្រាជ្ញាញាណជាខ្យល់ដង្ហើមរបស់ព្រះជាម្ចាស់ ប្រកបដោយឫទ្ធានុភាពនិងជារស្មីដ៏វិសុទ្ធចេញមកពីសិរីរុងរឿងនៃព្រះដ៏ខ្ពង់ខ្ពស់បំផុត**"។ ព្រះដ៏ខ្ពង់ខ្ពស់បំផុត ណែនាំឲ្យយើងមានប្រាជ្ញាឈ្លាសវៃ ជាមនុស្សដែលរឹងមាំ ជាមនុស្សដែលស្មោះត្រង់ ឲ្យយើងរស់នៅក្នុងបរិយាកាសហ្នឹង។ សាលារៀនទូទៅគិតតែអំពីខួរក្បាល និងមានសុខភាពខ្លះៗ ប៉ុន្តែនៅក្នុងសាលាកាតូលិកយើងបង្កើតបរិយាកាសប្លែក ដែលមានលក្ខណៈជាគ្រួសារមួយដែលចេះស្រឡាញ់គ្នាទៅវិញទៅមក ដែលធ្វើដំណើរជាមួយគ្នា ដែលបន្ថែមគុណធម៌សម្រាប់ជីវិតចិត្តស្មោះ ចិត្តស្រឡាញ់ ចិត្តបរិសុទ្ធ ចិត្តបម្រើ។ អរគុណបងប្អូនដែលបានយកចិត្តទុកដាក់ចូលនៅក្នុងបេសកកម្មនៃសាលាកាតូលិក ដើម្បីណែនាំឲ្យសិស្សានុសិស្សរបស់យើងអាចទៅជាមនុស្សប្លែកនៅក្នុងសង្គមនាថ្ងៃអនាគត។

ពេលយើងនិយាយអំពីអ្នកដឹកនាំ មានមេភូមិ មេឃុំ មេប៉ូលីស... ដែលពាក្យមេមកពីមនុស្សស្រី ដោយសារពីសម័យដើមនៅប្រទេសកម្ពុជាអ្នកដឹកនាំជាស្ត្រី ប៉ុន្តែសព្វថ្ងៃអ្នកដឹកនាំភាគច្រើនជាមនុស្សប្រុស។ ខ្ញុំសង្ឃឹម យុវនារីរបស់យើងនៅថ្ងៃអនាគតក្លាយទៅជាអ្នកដឹកនាំប្រសិនបើយើងអនុវត្តអ្វីដែលយើងបានស្តាប់នៅក្នុងអត្ថបទទីមួយនេះ ខ្ញុំជឿថាជីវិតរបស់យើងបន្តិចម្តងៗប្រែប្រួលនៅក្នុងរបៀបល្អ ដើម្បីទៅជាយុវនារីដែលពោរពេញដោយកម្លាំង ពោរពេញដោយសេចក្តីក្លាហាន ពោរពេញដោយប្រាជ្ញាឈ្លាសវៃ ជាអ្វីដែលសង្គមត្រូវការ។ កុំបោះបង់ចោលការសិក្សា ការអភិវឌ្ឍប្រទេសឆ្លងតាមការអភិវឌ្ឍសង្គម ដែលមានការអប់រំ ការសិក្សា សុខភាព...។ សព្វថ្ងៃ យើងមានយុវនារីច្រើនណាស់ដែលឈប់រៀនទៅធ្វើការនៅរោងចក្រ ធ្វើឲ្យអ្នកទាំងនោះគ្មានចំណេះដឹង នៅពេលអនាគតទៅជាម្តាយគេយើងគ្មានសមត្ថភាពដើម្បីណែនាំអប់រំកូនយើងឡើយ។ យើងធ្វើដូចម្តេច ដើម្បីរៀបចំអនាគតយើងដូចអ្វីដែលយើងកំពុងចាប់ផ្តើមនៅទីនេះ យើងអាចនិយាយថាសាលាយើងជារោងចក្រមួយពិសេស គឺរោងចក្រផលិតធនធានមនុស្សដ៏ពេញលក្ខណៈ។ យើងពោរពេញដោយមោទនភាព ពោរពេញដោយកម្លាំង យើងទូល

អង្វរព្រះជាម្ចាស់សូមព្រះអង្គប្រទានព្រះប្រាជ្ញាញាណ ដែលជាដង្ហើមរបស់ព្រះជាម្ចាស់ប្រកបដោយឫទ្ធានុភាព និងរស្មីដ៏ពិសេសមកគង់លើបងប្អូន។ អាម៉ែន៕